៣១.២. ការគ្រប់គ្រងរបស់ភ្នាក់ងារគណនេយ្យ ត្រូវស្ថិតក្រោមការត្រួតពិនិត្យនៃគណនេយ្យ កណ្តាលរបស់ធនាគារជាតិ និងក្រោមការត្រួតពិនិត្យនៃអគ្គាធិការដ្ឋានហិរញ្ញវត្ថុ ។

៣១.៣. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចចាត់តាំងអោយមានការត្រួតពិនិត្យរួមអធិការកិច្ច ឬពិនិត្យលើផ្នែកណាមួយ ដែលយល់ថាចាំបាច់ ក្នុងល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ពាក់ព័ន្ធ នឹងកិច្ចត្រួតពិនិត្យនេះ ។

## ជំពូកទី ៤

## អវសានបញ្ញត្តិ

**មាត្រា៣២.–**

៣២.១. បទបញ្ញត្តិទាំងឡាយ ដែលមានពីមុន ហើយផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

៣២.២. សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងរដ្ឋក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងស្ថាប័នដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តអោយបានសំរេចនូវអនុក្រឹត្យនេះ ។

៣២.៣. អនុក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខា និង ត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

* * *

## អនុក្រឹត្យ លេខ ៦៦ អនក្រ.បក

## ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់

## ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## រាជរដ្ឋាភិបាល

–បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៨៣ ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យលេខ នស/រកត/១០៩៤/៩០ ចុះថ្ងៃទី៣១ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២០ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៨៩៧/១៤៧ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ ១៩៩៧ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- តាមសំណើរបស់រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍
- តាមការឯកភាពរបស់គណៈរដ្ឋមន្ត្រី នាសម័យប្រជុំថ្ងៃទី២១ ខែ សីហា ឆ្នាំ ១៩៩៧

**សម្រេច**

## ជំពូក ១

## បទបញ្ញត្តិទូទៅ

**មាត្រា១.**– អនុក្រឹត្យនេះរៀបចំបណ្តាអង្គភាពនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍និងកំណត់បេសកកម្មរបស់ក្រសួង និងមុខការនៃអគ្គនាយកដ្ឋាន និងបណ្តានាយកដ្ឋាននានា ។

## ជំពូក២

## បេសកកម្ម និង រចនាសម្ព័ន្ធ

**មាត្រា២.–** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ប្រគល់បេសកកម្មអោយដឹកនាំ និងគ្រប់គ្រងវិស័យប្រៃសណីយ៍ និងទូរគមនាគមន៍ នៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣.–** ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានមុខងារ និងភារកិច្ចដូចតទៅ :

១–ប្រតិបត្តិសេវាកម្មអាជីវកម្មផ្នែកការងារមូលដ្ឋានខាងវិស័យប្រៃសណីយ៍និងទូរគមនាគមន៍

២–ធ្វើជាដៃគូរនៃសម្ព័ន្ធអាជីវកម្មផ្នែកទូរគមនាគមន៍និងការងារប្រៃសណីយ៍

៣–ផ្តល់អាជ្ញាប័ណ្ណ កសាងបញ្ញត្តិអធិការកិច្ច កសាងស្តង់ដា និងគ្រប់គ្រងរលកអាកាសវិទ្យុគ្រប់ប្រភេទ

៤–កសាងគោលនយោបាយ និង ផែនការអភិវឌ្ឍន៍វិស័យទូរគមនាគមន៍ និង ប្រៃសណីយ៍

៥–គ្រប់គ្រង ដឹកនាំការងារប្រៃសណីយ៍ និងការងារទូរគមនាគមន៍ទូទាំងប្រទេស

៦–ហត្ថលេខីជាមួយអន្តរជាតិខាងប្រៃសណីយ៍ និងទូរគមនាគមន៍ និងជាតំណាងរាជរដ្ឋាភិបាលក្នុងអង្គការចាត់តាំងអន្តរជាតិខាងប្រៃសណីយ៍ និង ទូរគមនាគមន៍

៧–បណ្តុះបណ្តាលអ្នកបច្ចេកទេសជំនាញគ្រប់ផ្នែកប្រៃសណីយ៍ និង ទូរគមនាគមន៍

**មាត្រា៤.–** ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ មានរចនាសម្ព័ន្ធដូចតទៅ :·

–ខុទ្ទកាល័យ

–នាយកដ្ឋានរដ្ឋបាលបណ្តុះបណ្តាល និង ហិរញ្ញវត្ថុ

-អធិការដ្ឋាន
-អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍
-គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល
-ទូរគមនាគមន៍កម្ពុជា
-ប្រៃសណីយ៍កម្ពុជា

អង្គការលេខរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ជាឧបសម្ព័ន្ធរបស់អនុក្រឹត្យនេះ ។

## ជំពូក ៣

## ខុទ្ទកាល័យ

**មាត្រា៥.-** ខុទ្ទកាល័យនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ទទួលបន្ទុកបេសកកម្មទាំងឡាយដែលកំណត់តាមបទបញ្ញត្តិនៃអនុក្រឹត្យ លេខ២០ អនក្រ-បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន ។

## ជំពូក៤

## អធិការដ្ឋាន

**មាត្រា៦.-** អធិការដ្ឋានរបស់ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ ទទួលបន្ទុក :

-ធ្វើអធិការកិច្ចជាប្រចាំទៅលើគ្រប់អង្គភាពក្រោមឱវាទក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

-ធ្វើរបាយការណ៍ជូនរដ្ឋលេខាធិការ ពីការប្រព្រឹត្តិទៅរបស់អង្គភាពដែលបានធ្វើអធិការកិច្ចហើយនោះ និងពីមធ្យោបាយកែលំអការប្រព្រឹត្តិទៅរបស់អង្គភាពទាំងនោះ ។

-ប្រតិបត្តិភារកិច្ចតាមកាលដែលរដ្ឋមន្ត្រី ឬរដ្ឋលេខាធិការបានប្រគល់ទុកចិត្តអធិការដ្ឋានដឹកនាំដោយអធិការមួយនាក់ អាចអមដោយអធិការរងមួយ ឬច្រើនរូបជួយធ្វើការទៅតាមការចាំបាច់ ។

## ជំពូក ៥

## នាយកដ្ឋានរដ្ឋបាល បណ្តុះបណ្តាល និង ហិរញ្ញវត្ថុ

**មាត្រា៧.-** នាយកដ្ឋានរដ្ឋបាល បណ្តុះបណ្តាល និងហិរញ្ញវត្ថុ ទទួលបន្ទុក :

ក-ក្នុងវិស័យរដ្ឋបាល :

-សំរបសំរួលសកម្មភាពគ្រប់ផ្នែករបស់ក្រសួងនៅថ្នាក់កណ្តាល និងរវាងថ្នាក់កណ្តាល និងអង្គភាពមូលដ្ឋានក្រោមនិវាទ

-គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់ក្រសួង

-ធានាប្រសិទ្ធភាព សុវត្ថិភាពរដ្ឋបាល និងគ្រប់គ្រងការងារសង្គមរបស់ក្រសួង

-សរុប និងធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់ក្រសួង.

ខ-ក្នុងវិស័យគ្រប់គ្រងបុគ្គលិក :

-គ្រប់គ្រងផ្នែករដ្ឋបាល មន្ត្រីរាជការនិងភ្នាក់ងាររាជការរបស់ក្រសួង ដោយទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

-រៀបចំរាល់លិខិតរដ្ឋបាលសំរាប់ការគ្រប់គ្រងអាជីព

-ធ្វើកម្មវិធីពីតំណែងឯកទេស និងធនធានមនុស្សរបស់ក្រសួង

-វាយតម្លៃតម្រូវការក្នុងការបណ្តុះបណ្តាលបុគ្គលិក

-រៀបចំនយោបាយបណ្តុះបណ្តាលដំបូង និងបន្ត ដោយធ្វើទំនាក់ទំនងនឹងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និងអនុវត្តន៍នយោបាយនោះ

-រៀបចំស្ថិតិលើការគ្រប់គ្រងបុគ្គលិក និងតារាងពតិមានប្រតិបត្តិ

គ-មជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសប្រៃសណីយ៍និងទូរគមនាគមន៍ :

-រៀបចំកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈអ្នកបច្ចេកទេសប្រៃសណីយ៍និងទូរគមនាគមន៍

-បណ្តុះបណ្តាលកម្មករ អ្នកបច្ចេកទេស អ្នកនាំសារ លេខាធិការ អ្នកត្រួតពិនិត្យ និងរៀបចំបង្រៀនវិក្រឹតការដល់បុគ្គលិក

-រៀបចំបង្រៀនពតិមានវិទ្យា និងបង្រៀនភាសាបរទេស

ឃ-ក្នុងវិស័យគ្រប់គ្រងសំភារៈ និង បរិក្ខារ :

-ប្រមូលផ្តុំតម្រូវការ ធ្វើកម្មវិធីចំណាយគ្រប់គ្រងការរៀបចំផ្គត់ផ្គង់សំភារៈ និងបរិក្ខាររបស់ក្រសួង

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសំភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ

-គ្រប់គ្រងយានដ្ឋាន និងយានយន្តរបស់រដ្ឋដែលប្រគល់ជូនក្រសួង ព្រមទាំងធ្វើកម្មវិធីចំណាយ និងបែងចែកប្រេងឥន្ធនៈ និងគ្រឿងបន្លាស់

-ទទួល និងបែងចែកបរិក្ខារជូនដល់បណ្តាអង្គភាពខេត្ត-ក្រុងនានា

-កាន់បញ្ជីជាប្រចាំនូវសលាកប័ត្រ និងគណនេយ្យរូបធាតុ

-ពតិមានវិទ្យា សកម្មភាពខាងហិរញ្ញវត្ថុ និងបន្ទុកគណនី

-ត្រួតពិនិត្យបច្ចេកទេសនៃការប្រតិបត្តិ លទ្ធកម្មសាធារណៈ

ង-ក្នុងវិស័យគ្រប់គ្រងបន្ទុកគណនី និងហិរញ្ញវត្ថុ :

-លើកគំរោងថវិកាក្រសួង និងតាមដានរំលឹកពីការប្រតិបត្តិ

-ប្រមូលផ្តុំ និងសំរបសំរួលជំពូកថវិកា

-តាមដានរំលឹកការគ្រប់គ្រងគណនីពិសេស

-ប្រមូលផ្តុំ និងសំរបសំរួលរាល់ចំណាយរបស់ក្រសួង

-គ្រប់គ្រងបន្ទុកគណនីរបស់ការអនុវត្តន៍លទ្ធកម្មសាធារណៈ

## ជំពូក ៦

## អគ្គនាយកដ្ឋានប្រៃសណីយ៍ និង ទូរគមនាគមន៍

**មាត្រា៨.-** អគ្គនាយកដ្ឋានប្រៃសណីយ៍ និងទូរគមនាគមន៍ ទទួលបន្ទុកធ្វើទំនាក់ទំនងសំរបសំរួលគ្រប់គ្រងរលកអាកាសវិទ្យុគមនាគមន៍ និងអាជ្ញាប័ណ្ណ នយោបាយទូរគមនាគមន៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ ត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍ និងនយោបាយប្រៃសណីយ៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ ។

អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ ដឹកនាំដោយអគ្គនាយកម្នាក់ ដែលអាចអមដោយអគ្គនាយករង ជាជំនួយការតាមការចាំបាច់ ។

អគ្គនាយកដ្ឋានប្រៃសណីយ៍និងទូរគមនាគមន៍ មាននាយកដ្ឋានចំណុះ ចំនួន៤ :

-នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុគមនាគមន៍ និងអាជ្ញាប័ណ្ណ
-នាយកដ្ឋាននយោបាយទូរគមនាគមន៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ
-នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍
-នាយកដ្ឋាននយោបាយប្រៃសណីយ៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ

**មាត្រា៩.-** នាយកដ្ឋានគ្រប់គ្រងរលកអាកាសវិទ្យុគមនាគមន៍ និងអាជ្ញាប័ណ្ណ ទទួលបន្ទុកតាក់តែងវិធាននៃការប្រព្រឹត្តិទៅនៃរលកអាកាសវិទ្យុ ជាពិសេស នាយកដ្ឋានត្រូវ :

-រៀបចំតម្លើងស្តង់ដាវិទ្យុគមនាគមន៍
-តាក់តែងឯកសារគំរូសំរាប់ផ្តល់ការយល់ព្រមដល់ការប្រើប្រាស់ស្តង់ដា
-តាក់តែងការអនុវត្តន៍ពតិមានវិទ្យា
-សំរបសំរួលក្នុងការប្រើប្រាស់រយៈពេលវែង ស៊ីចរលកវិទ្យុ និងក្នុងការបញ្ចូលស៊ីចរលកវិទ្យុក្នុងទំនាក់ទំនងអន្តរជាតិ
-ត្រួតពិនិត្យ និងតាមដានការប្រើប្រាស់រលកវិទ្យុ
-បែងចែកអាជ្ញាប័ណ្ណជូនបណ្តាការីដែលស្នើសុំ
-ដោះស្រាយវិវាទ និងវិបត្តិដែលមានជាមួយបណ្តាការី
-ផ្តល់ការយល់ព្រមលើបរិក្ខាររបស់បណ្តាការីដែលត្រូវតភ្ជាប់ទៅនឹងបណ្តាញទូរស័ព្ទ

**មាត្រា១០.-** នាយកដ្ឋាននយោបាយទូរគមនាគមន៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ ទទួលបន្ទុកតាក់តែងនយោបាយរយៈពេលវែង កំណត់បញ្ជីតម្លៃផ្សេងៗ រៀបចំនិងការតាមដានទំនាក់ទំនងអន្តរជាតិក្នុងវិស័យនេះ ។ ជាពិសេស នាយកដ្ឋានត្រូវ :

-កំណត់នយោបាយរបស់កម្ពុជា អំពីទូរគមនាគមន៍រយៈពេលវែង និងតាក់តែងច្បាប់ ស្តីអំពីទូរគមនាគមន៍ ។
-តាមដានពីការបោះទីតាំងអង្គភាពទូរស័ព្ទមូលដ្ឋានរបស់គ្រឹះស្ថានសាធារណៈទូរគមនាគមន៍ កម្ពុជានិងរបស់បណ្តាការីនៅតាមខេត្ត និងស្រុកនីមួយៗ
-រៀបចំរបាយការណ៍ប្រចាំខែរបស់ក្រសួង ស្តីពីការរីកចំរើនរបស់អង្គភាពមូលដ្ឋានទាំងនោះ

-តាក់តែងបញ្ជីតម្លៃផ្សេងៗ ដោយយកចិត្តទុកដាក់ពីទិដ្ឋភាពសង្គម និងតំបន់
-ជាតំណាងអោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងការប្រជុំជាអន្តរជាតិ ស្តីពីបញ្ជីតម្លៃជាទ្វេភាគី ពហុភាគីមានជាអាទិ៍ សហភាពទូរគមនាគមន៍អន្តរជាតិ
-ជាតំណាងអោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍នៅក្នុងការប្រជុំអន្តរជាតិនានា ។
-សំរបសំរួលកិច្ចព្រមព្រៀងទ្វេភាគីក្នុងវិស័យទូរគមនាគមន៍

**មាត្រា១១.**- នាយកដ្ឋានត្រួតពិនិត្យការគ្រប់គ្រងប្រៃសណីយ៍និងទូរគមនាគមន៍ទទួលបន្ទុកតាក់តែងវិធានការណ៍នៃការប្រព្រឹត្តិទៅក្នុងការបញ្ជូនបញ្ញើផ្សេងៗ លិខិត និងឯកសារ ។ ជាពិសេស នាយកដ្ឋានត្រូវ :
-កំណត់ពីតម្រូវការនៃសេវាសាធារណៈ
-កំណត់ពីបទបញ្ជាក្នុងការប្រជែងគ្នា
-ផ្តល់ការយល់ព្រមលើបញ្ជីតម្លៃប្រៃសណីយ៍

**មាត្រា១២.**- នាយកដ្ឋាននយោបាយប្រៃសណីយ៍ និយ័ត និងទំនាក់ទំនងអន្តរជាតិ ទទួលបន្ទុកតាក់តែងនយោបាយ រយៈពេលវែង និងតាមដានទំនាក់ទំនងអន្តរជាតិក្នុងវិស័យប្រៃសណីយ៍ ។ ជាពិសេសនាយកដ្ឋានត្រូវ :
-កំណត់នយោបាយរបស់កម្ពុជា អំពីប្រៃសណីយ៍រយៈពេលវែង និងតាក់តែងច្បាប់ស្តីពីប្រៃសណីយ៍
-ជាតំណាងអោយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ក្នុងការប្រជុំអន្តរជាតិនានា
-សំរបសំរួលកិច្ចព្រមព្រៀងទ្វេភាគីក្នុងវិស័យប្រៃសណីយ៍

## ជំពូក ៧

## អង្គភាពមូលដ្ឋាន

**មាត្រា១៣.**-នៅតាមបណ្តាខេត្ត-ក្រុងនីមួយៗ មានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ ខេត្ត-ក្រុង មួយដែលទទួលបន្ទុកអនុវត្ត និងសំរបសំរួលសកម្មភាពរបស់ក្រសួង ។

## ជំពូក ៨

## គ្រឹះស្ថានសាធារណៈក្រោមអាណាព្យាបាល

**មាត្រា១៤.**_ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ត្រូវមានគ្រឹះស្ថានសាធារណៈពីរដែលមានឧបនិស្ស័យសេដ្ឋកិច្ច ក្រោមអាណាព្យាបាល ដូចតទៅ :

_គ្រឹះស្ថានសាធារណៈទូរគមនាគមន៍កម្ពុជា

_គ្រឹះស្ថានសាធារណៈប្រៃសណីយ៍កម្ពុជា

**មាត្រា១៥.**_ការរៀបចំនិងការប្រព្រឹត្តិទៅរបស់គ្រឹះស្ថានសាធារណៈខាងលើនីមួយៗ ត្រូវកំណត់ដោយអនុក្រឹត្យ ដែលបញ្ជាក់ពីលក្ខន្តិកៈដោយឡែករបស់ខ្លួន ដោយអនុលោមតាមព្រះរាជក្រម ជស/រកម/០៦៩៦ ចុះថ្ងៃទី១៧-៦-១៩៩៦ ស្តីពីលក្ខន្តិកៈទូទៅនៃសហគ្រាសសាធារណៈ ។

## ជំពូក ៩

## អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ

**មាត្រា១៦.**_អង្គភាពត្រួតពិនិត្យហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមល័ក្ខខ័ណ្ឌនៃបទបញ្ជាកំណត់ក្នុងអនុក្រឹត្យលេខ ៨១ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតស្ថាប័នត្រួតពិនិត្យហិរញ្ញវត្ថុលើការចំណាយថវិកាក្នុងបណ្តាក្រសួង ។

## ជំពូក ១០

## អវសានប្បញ្ញត្តិ

**មាត្រា១៧:** ការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រសួងនៅរដ្ឋបាលកណ្តាល ចាប់ពីថ្នាក់ក្រោមនាយកដ្ឋានចុះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ។

**មាត្រា១៨.**_បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១៩**._សហរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការទាំងអស់ដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ។

**មាត្រា២០** ._អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧

នាយករដ្ឋមន្ត្រីទី១ នាយករដ្ឋមន្ត្រីទី២

ហត្ថលេខានិងត្រា

**អ៊ុង ហួត** **ហ៊ុន សែន**

# អង្គការលេខរបស់ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍

